# បទពិសោធន៍កំចាត់មមាចត្នោត ដោយប្រើថ្នាំពុលធម្មជាតិ

លោកពូ **កុយ សាម៉ន** អាយុ ៤០ ឆ្នាំ ជាកសិករទទួលបានចំណាត់ថ្នាក់លេខ ២ ក្នុងការបរង្កើតគំនិតផ្តួចផ្តើមថ្មីនៅក្នុងមូលដ្ឋានរបស់កម្មវិធីប្រូលីណូវ៉ា កម្ពុជា ដែលរស់នៅភូមិស្រម៉ុក ឃុំពន្លៃ ស្រុកអង្គរបុរី ខេត្តតាកែវ ។ គាត់បានសហការជាមួយអង្គការ សេដាក តាំងពីខែវិច្ឆិកា ឆ្នាំ ២០០៤ ។ គាត់មានបទពិសោធន៍ក្នុងការការពារ និងកំចាត់មមាចត្នោតដោយប្រើថ្នាំពុលធម្មជាតិដែលផ្សំដោយខ្លួនឯង ។ បទពិសោធន៍នេះជាគំនិតច្នៃប្រឌិតផ្ទាល់របស់លោកពូ ដោយផ្អែកតាមចំណេះដឹងមួយចំនួនដែលទទួលបានពីការបណ្តុះបណ្តាលរបស់ អង្គការ សេដាក និងការអានទស្សនាវដ្តីកសិករ ស្តីពីផលប្រយោជន៍នៃការប្រើប្រាស់ថ្នាំពុលធម្មជាតិ។



ទឹកថ្នាំដែលបានផលិតហើយ

## ១.មូលហេតុនៃការអនុវត្តបច្ចេកទេសនេះ

មូលហេតុសំខាន់ដែលលោកពូអនុវត្តន៍បច្ចេកទេសនេះ ដោយសារស្រែរបស់គាត់មានមមាចត្នោតនៅ ហើយមិនដឹងថាត្រូវធ្វើយ៉ាងណា ។ មុនដំបូងគាត់បានសាកល្បងប្រើថ្នាំពុលគីមីដែលគាត់បានទៅសុំនៅមន្ទីរកសិកម្មខេត្ត តែលទ្ធផលចុងក្រោយគឺបរាជ័យ ក្រោយមកមមាចត្នោតកាន់តែរីករាលដាលច្រើនឡើង។ គាត់ក៏សម្រេចចិត្តផ្សំថ្នាំពុលពីធម្មជាតិយកមកប្រើ ។

## ២.ធាតុផ្សំ និងរបៀបផ្សំ

### ២.១ វត្ថុធាតុដើម និងបរិមាណសម្រាប់ផ្សំ

- មើមខ្ញី ២ គីឡូក្រាម
- មើមស្លែងជង់ដឹង ១ គីឡូក្រាម
- មើមក្តួច ២ គីឡូក្រាម
- មើមរំដេង ២ គីឡូក្រាម
- វល្លិ៍បណ្តូលពេជ ២ គីឡូក្រាម
- សំបកកន្ទួត ២ គីឡូក្រាម
- សំបកថ្មាន់ ២ គីឡូក្រាម
- សំបកស្តៅ ២ គីឡូក្រាម
- សំបកក្រសាំង ២ គីឡូក្រាម



សកម្មភាពកូរទឹកថ្នាំនៅពេលរក្សាទុក

| | | | |
|---|---|---|---|
| - សំបកស្ដែងធំ | ២ គីឡូក្រាម | - ដីគ្រប់មុខ | ១ គីឡូក្រាម |
| - ស្លឹកទៀបស្រុក | ៥ គីឡូក្រាម | - ស្លឹកគ្រៃគ្រឿង | ២ គីឡូក្រាម |
| - ស្លឹកទន្ទ្រានខែត្រ | ៥ គីឡូក្រាម | - វល្លិ៍កំបោរ | ២ គីឡូក្រាម |
| - ស្លឹកល្ហុងហុបផ្លែ | ៥ គីឡូក្រាម | - ផ្លែស្លាខ្ចី | ១ គីឡូក្រាម |
| - ស្លឹកល្ហុងខ្វង | ៥ គីឡូក្រាម | - ដើមដៃប្រកន់ | ៥ គីឡូក្រាម |
| - ដើម និងស្លឹកម្រះព្រៅ | ១ គីឡូក្រាម | - ស្លឹកក្រូចសើច | ០,៥ គីឡូក្រាម |

### ២.២ សម្ភារៈប្រើប្រាស់សម្រាប់ផ្សំ

ក្នុងការធ្វើថ្នាំនេះ គាត់ប្រើសម្ភារៈមួយចំនួនដូចជា ថ្នាំងធំមួយ គម្របថ្នាំង កាំបិត ឈើទ្រាប់ ចង្ក្រានធំ ឬ គុក ឧបករណ៍សម្រាប់បាញ់ថ្នាំ ប្លាស្ទិក ឬ កន្ទេលចាស់សម្រាប់ប្រមូលធាតុផ្សំ និងឈើវាស់ ។

### ២.៣ របៀបផ្សំ

- យកសារធាតុទាំងអស់ខាងលើដែលមានទម្ងន់សរុប ៥១,៥ គីឡូក្រាម មកកាប់ចិញ្ច្រាំឲ្យម៉ដ្ឋ រួចដាក់ដាំក្នុងថ្នាំង ដោយដាក់ទឹក ២០៦ លីត្រ ហើយដាំរម្ងាស់ឲ្យនៅសល់ត្រឹមតែ ២៥,៧៥ លីត្រ (មានន័យថា បើយើងប្រើធាតុផ្សំអស់ ១ គីឡូក្រាម ត្រូវដាក់ទឹកចំនួន ៤ លីត្រ ហើយរម្ងាស់យកតែកន្លះលីត្រ)



ពណ៌ទឹកថ្នាំក្រោយពីកូរហើយ

- នៅពេលថ្នាំរម្ងាស់រួចរាល់ត្រូវច្រោះយកកាកថ្នាំចេញ ហើយទុកវាឲ្យត្រជាក់ដោយរក្សាទុកឲ្យបានល្អសម្រាប់ប្រើប្រាស់ពេលត្រូវការ ។

## ៣.ការប្រើប្រាស់

គាត់ផលិតថ្នាំនេះនៅដើមឆ្នាំ មុនសាបសំណាប និងស្ទូង ដើម្បីប្រើការពារជាមុន

- ក្រោយពេលដាំរម្ងាស់រួចរាល់ គាត់រក្សាទុករយៈពេលពី ៤ ទៅ ៥ ម៉ោងសិន ដើម្បីឲ្យទឹកថ្នាំត្រជាក់ល្អមុននឹងយកទៅប្រើ ហើយត្រូវទុកនៅក្នុងម្លប់ផុតពីដៃក្មេង និងឆ្ងាយពីសត្វមាន់
- ទឹកថ្នាំនេះអាចរក្សាគុណភាពបានដូចដើមក្នុងកំឡុងពេល ៣ ខែក្រោយ ។ តែក្រោយរយៈពេលនេះ គ្រាន់តែគុណភាពវាខ្សោយជាងមុនបន្តិច ។

### ៣.៣ បរិមាណ និងរបៀបប្រើ

យើងអាចប្រើថ្នាំនេះសម្រាប់ការពារ និងកំចាត់សត្វជាច្រើនផ្សេងទៀតក្រៅពីមមាចត្នោត ដូចជា មមាចខៀវ ទ្រីប កន្ធូប មេអំបៅ រុយ កន្ទុំរុយ និងចៃនៅលើសណ្ដែក ឬ ត្រសក់ ។ នៅពេលបាញ់ថ្នាំនេះ ត្រូវលាយជាមួយសាប៊ូ ១ ស្លាបព្រាបាយ ព្រោះវាជួយឲ្យមានភាពរអិលងាយស្រួលបាញ់ និងធ្វើឲ្យទឹកថ្នាំស្អិតជាប់នឹងស្លឹកស្រូវបានយូរ ។

- ករណីបាញ់សម្រាប់ការពារ ត្រូវយកទឹកថ្នាំនេះចំនួន ៣ លីត្រ លាយជាមួយទឹក ៨៤ លីត្រ បាញ់នៅលើដីស្រែទំហំ ៥ អារ
- បើប្រើសម្រាប់កំចាត់ ប្រើទឹកថ្នាំចំនួន ១៥ លីត្រ លាយជាមួយទឹក ៦០ លីត្រ បាញ់នៅលើដីស្រែ ទំហំ ១៧ អារ (បាញ់ ២ ទៅ ៣ ថ្ងៃជាប់ៗគ្នា តែពេលបាញ់ម្តងៗត្រូវប្រើទឹកថ្នាំត្រឹមតែ ៥ លីត្រ លាយជាមួយទឹកធម្មតា ២០ លីត្រ)
- ករណីមានមមាចត្នោតច្រើន (រហូតមើលឃើញឡើងព្រីសម្បុរ) យើងត្រូវយកទឹកថ្នាំនេះ ២៤ លីត្រ លាយទឹកចំនួន ៤០ លីត្រ បាញ់នៅលើដីទំហំ ១៧ អារ
- មុនពេលបាញ់ត្រូវយកជើង ឬ ឈើវាសទះឲ្យមមាចត្នោតធ្លាក់មកទើលើទឹកសិន ហើយបាញ់ថ្នាំនេះនៅពេលមេឃកំពុងក្តៅខ្លាំង ។ ត្រូវបាញ់ពីលើខ្យល់ បាញ់នៅផ្នែកខាងក្រោមនៃដើមស្រូវ តាមដង្កៀបគុម្ពស្រូវ
- បើសិនជាមានភ្លៀងធ្លាក់ច្រើននៅក្រោយពេលយើងបាញ់ថ្នាំនេះ យើងត្រូវបាញ់ម្តងទៀតនៅពេលស្អែកឡើង។

## ៤.បច្ចេកទេសផ្សេងៗទៀតក្នុងការកំចាត់មមាចត្នោត

ក្រៅពីនេះ គាត់ប្រើវិធីសាស្ត្រផ្សេងៗទៀតសម្រាប់កំចាត់មមាចត្នោតនេះគឺ:

- ទី ១ អាចប្រើប្រេងម៉ាស៊ីនចាស់ៗដែលគេលែងត្រូវការ ១ លីត្រ លាយជាមួយកន្ទក់ ២ គីឡូក្រាម បាចនៅលើផ្ទៃដីទំហំ ២០ អារ រួចដាក់ខ្សែគោអូសនៅលើស្រូវធ្វើឲ្យមមាចត្នោតធ្លាក់ទៅទុំនឹងកន្ទក់ដែលជាប់ប្រេងម៉ាស៊ីនអាចឲ្យវាងាប់ពី ៧០ ទៅ ៨០ ភាគរយ ធ្វើរបៀបនេះពី ២ ទៅ ៣ ដង នឹងអស់មមាចត្នោតពីស្រែ
- ទី ២ ប្រើកូនទាដែលមានអាយុ ១ ខែ ចុះក្រោម ឲ្យចុះរកស៊ីក្នុងស្រែ
- ទី ៣ ថ្នាំពុលផ្សំពីរុក្ខជាតិ ដោយបន្ថែមសារធាតុមួយចំនួនដូចជា លាមកគោ ១ បង្គី វល្លិ៍មាស ៥ គីឡូក្រាម ថ្នាំខ្លាំង ៣ គីឡូក្រាម កំបោរស ២ គីឡូក្រាម ត្រួយរាំង ២៥ គីឡូក្រាម ផ្លែស្លាក់ ២ គីឡូក្រាម និងទឹកនោមដាក់ឲ្យលិចថ្នាំ លើធាតុផ្សំដែលមានស្រាប់នៅខាងលើ ។ ត្រាំចោលដោយឧស្សាហ៍កូរត្រឡប់ក្នុង ១ថ្ងៃ កូរម្តង ។ ២៥ ទៅ ៣០ ថ្ងៃក្រោយ អាចយកមកប្រើបាន ដោយធាតុផ្សំទាំងអស់ត្រូវបានរលួយ និងទឹកថ្នាំមិនមានក្លិនស្អុយ ហើយមានពណ៌ថ្លាដូចជាពណ៌ទឹកតែ ។ ទឹកថ្នាំនេះអាចទុកប្រើបានរហូតដល់ ៨ ខែ ទៅ ១ ឆ្នាំក្រោយផលិត ។

## ៥.ចំណាប់អារម្មណ៍

តាមប្រសាសន៍លោកពូបានបញ្ជាក់ថា ការអនុវត្តតាមបច្ចេកទេសនេះមានការឃាត់ទៀយ ព្រោះមានធាតុផ្សំមួយចំនួនពិបាកក្នុងការដើររក តែយើងនៅតែអាចធ្វើបានដោយខ្លួនឯងដែលអាចសន្សំបានប្រាក់មួយចំនួន ក្រៅពីនេះ លោកពូក៏អាចរកចំណូលបន្ថែមតាមរយៈការផលិតថ្នាំនេះលក់ទៅឲ្យអ្នកត្រូវការផ្សេងទៀត ។ ម្យ៉ាងទៀត ថ្នាំនេះមិនបណ្តាលឲ្យប៉ះពាល់ដល់សុខភាពអ្នកផលិត និងអ្នកបរិភោគ បរិស្ថាន សត្វមានប្រយោជន៍ និងដី ហើយអ្វីដែលសំខាន់នោះគឺអាចកំចាត់មមាចត្នោតបានជោគជ័យ និងធ្វើឲ្យដំណាំស្រូវកាន់តែល្អ ។

**សយ សុភត្រា**